# លោក កឹម សុខា នៅឯណា ?

សំនួរនេះ សមនឹងលើកយកមកពិចារណា ក្នុងគំនិត រកការពិត អំពីវត្តមាន ជាប្រយោជន៏ របស់លោក កឹម សុខា នៅក្នុងការតស៊ូដើម្បីតម្រង់វិញ នូវលទ្ធិប្រជាធិបតេយ្យ។ ជារាងកាយសព្វថ្ងៃនេះ លោក កឹម សុខា ជាអ្នកទោសមនសិការ ជាប់ឃុំឃាំងនៅក្នុងភូមិគ្រឹះរបស់គាត់។ ស្ថានភាពនេះ ជាជម្រើសផ្ទាល់របស់គាត់។ មូលហេតុ គឺសុខភាព, ពោលថា ជម្ងឺរបស់គាត់ ត្រូវចាំបាច់មានការពិនិត្រវេជ្ជសាស្ត្រទៀងទាត់, ដែលនាំអោយគាត់ សំរេចចិត្តយល់ព្រម ទទួលយកលក្ខខណ្ឌតឹងរ៉ឹងមួយចំនួន របស់អាជ្ញាធរពាក់ព័ន្ធ ដើម្បីផ្ទេរទីកន្លែងឃុំឃាំង។ តាមគំនិតមនុស្សជាតិ ជម្រើសបែបនេះ ជាជម្រើសសមហេតុផល ព្រោះគាត់ជាមនុស្ស ហើយគ្មាននរណា អាចរិះគន់បាននោះឡើយ, តែតាមគំនិតនយោបាយ វាបង្ហាញ នូវជោគជ័យនៃរបបនៅភ្នំពេញ។ តែត្រូវដឹងថាលោក កឹម សុខា គាត់គ្មានចរឹត ដូចលោក Nelson Mandela និង Mahatma Gandhi នោះដែរ។ ដូច្នេះ តើនឹងអាចមាន សម្បទានបែបណាទៀតដែលលោក កឹម សុខា ធ្លាប់បានធ្វើកន្លងមក ដើម្បី សុរុះឌ្ឍិកម្ម សំរាប់ការរស់នៅផ្ទាល់របស់គាត់។ ជារូបកាយ គាត់ជាជនរងគ្រោះដ៏អយុត្តិធម៏ជាទីបំផុត តែជាស្មារតីអង់អាច ក្នុងការតស៊ូនយោបាយវិញ, ចម្លើយ វាមិនទាន់មាននៅឡើយ បើយកអតីតកាលជាសម្លាក។ តែពេលឥឡូវនេះ ប្រជាពលរដ្ឋខ្មែរ ត្រូវការអ្នកដឹកនាំមានសក្តាភាព ខុសពីបច្ចុប្បន្ន !៕

ឧប សៅ សង្ហា                    គំនិត                    ១៣ កក្កដា ២០១៨